ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាវិនិច្ឆ័យរឿងរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៣៥៨

ចុះថ្ងៃទី១១ខែធ្នូឆ្នាំ១៩៩៨

សាលដីកា

លេខ : ១៥៥

ចុះថ្ងៃទី៣១ខែសីហាឆ្នាំ១៩៩៩

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ៣១ ខែ-សីហា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក ប៉ែន ស៊ុន ជាចៅក្រម

៣- លោក វេឿល មួន ជាចៅក្រមរបាយការណ៍

៤- លោក ជីវ កេង ជាចៅក្រម

៥- លោក ស៊ិន គឹម ជាចៅក្រម

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ៥៣៦ ចុះថ្ងៃទី ១៧ ខែសីហា -ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៧១ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ស៊ិន ហ៊ាង ភេទស្រី អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរលក់អង្ករ ទីលំនៅភូមិអូរតាគាំ២ ឃុំទួលតាឯក ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ ស៊ិន "ស" ម្តាយឈ្មោះ គឹម ហ៊ួរ "ស" ។

និងចុង បណ្តឹងសាទុក្ខឈ្មោះ វី យាន ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរមេឃុំឈើទាល ទីលំនៅភូមិកំពង់ឆ្លង ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ។ ឪពុកឈ្មោះ វី យុន "ស" ម្តាយឈ្មោះ យឹម ពេង "រ" ។

ឈ្មោះ វី យាន បានផ្ទេរសិទ្ធិអោយទៅឈ្មោះ សូ សេង ។

កម្មវត្ថុបណ្តឹង: ប្តឹងទាមទារផ្ទះ និង ដី

តាមបណ្តឹងសាទុក្ខលេខ ៣៣៩ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ១៩៩៨ របស់អ្នកស្រី-ស៊ិន ហ៊ាង បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ៥៣៦ ចុះថ្ងៃទី១៧ ខែសីហា-ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៥៨ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩៨របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៣.០១.៨២ អ្នកស្រី ស៊ុន ហ៊ាង ប្ដឹងថា : ផ្ទះ និង ដីនេះខ្លួនជាអ្នកចូលមករស់នៅពីឆ្នាំ ១៩៧៩ លុះដល់ឆ្នាំ ១៩៨០ លោក មេភូមិឈ្មោះ ទិម ប៊ុនធី បានមកសុំផ្ទះនោះធ្វើជាសាលារៀនបណ្ដោះអាសន្នសិន ទំរាំដល់សាលារៀនធ្វើហើយ និង ប្រគល់អោយគ្រួសារខ្លួនវិញ ។ ពេលសាលារៀនធ្វើហើយខ្លួនបានទៅសួរគាត់ថាផ្ទះនេះជាប់ធ្វើមន្ទីរសុខាភិបាលឃុំឈើទាលហើយ ។ ក្រោយមកមានការខ្វះខាតរដ្ឋអំណាចចេះតែយកផ្ទះខ្លួនផ្លាស់ប្ដូរធ្វើជាកន្លែងប្រើប្រាស់ពីរូបភាពមួយ ជាបន្តបន្ទាប់ពុំព្រមប្រគល់អោយខ្លួនសោះ ។ ក្នុងរឿងនេះខ្លួនសុំទាមទារយកផ្ទះនេះវិញព្រោះបច្ចុប្បន្នខ្លួនពុំមានផ្ទះស្នាក់នៅទេ ។

បានឃើញសាលក្រមលេខ ១៤៨ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៨៥ របស់តុលាការខេត្តបាត់ដំបងដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ក. ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ០៣.០១.១៩៨២ របស់ដើមចោទឈ្មោះស៊ុន ហ៊ាង ប្ដឹងសុំគ្រប់គ្រងកាន់កាប់ផ្ទះ និង ដីទំនាស់ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

ខ. ទទួលស្គាល់លិខិតលេខ ៣៨០ស.ប.ណ ចុះថ្ងៃទី ០១.៤.១៩៨៥ របស់អភិបាលស្រុកបាណន់ ស្ដីពីការចាត់តាំងអ្នកដំណើរក្ដីទុកជាត្រឹមត្រូវតាមច្បាប់ ។

គ. ទទួលយកសំណូមពររបស់ចុងចម្លើយនាពេលសវនាការប្ដឹងសុំគ្រប់គ្រងកាន់កាប់ផ្ទះ និង ដីទំនាស់ជាកម្មសិទ្ធិ និង ប្ដឹងសុំបែងចែកដីទំនាស់មួយចំណែកដែលមិនប៉ះពាល់ដល់ផ្ទះទំនាស់ផ្ដល់អោយដើមចោទជាកម្មសិទ្ធិ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ប្រគល់ផ្ទះទំនាស់ទំហំ ៩,៣៥ម គុណ ៩,០០ម ស្ថិតនៅភូមិបាយដំរាំ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង អោយដល់ចុងចម្លើយគឺគណៈបក្សប្រជាជនប្រចាំស្រុកបាណន់គ្រប់គ្រងកាន់កាប់ជាកម្មសិទ្ធិ ចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

៣- បែងចែកដីទំនាស់ស្ថិតនៅភូមិបាយដំរាំ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង តាមរយៈបណ្ដោយដីពីកើតទៅលិចជាពីរ គិតយកជាមូលដ្ឋានតាមប្លង់បង្ហាញទីតាំងដីទំនាស់ ចុះថ្ងៃទី ២២.៦.៨៥ និងផ្ដល់ជាកម្មសិទ្ធិដល់ដើមចោទ និង ចុងចម្លើយតាមទំហំ និង ប្រវែងជ្រុងនិមួយៗដូចតទៅ :

ក. ដើមចោទឈ្មោះ ស៊ុន ហ៊ាង ផ្ដល់ជាកម្មសិទ្ធិនូវដីទំនាស់ប៉ែកខាងជើងគឺ: ជ្រុងខាងកើតប្រវែង ១២,០០ម ជ្រុងខាងលិចប្រវែង ១២,០០ម ជ្រុងខាងជើងប្រវែង ៦៧,២០ម ជ្រុងខាងត្បូងប្រវែង ៦៦,៥០ម តាមសំណូមពររបស់ចុងចម្លើយគិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

ខ. ចុងចម្លើយគណៈប្រជាជនប្រចាំស្រុកបាណន់ផ្ដល់ជាកម្មសិទ្ធិនូវដីទំនាស់ប៉ែកខាងត្បូងគឺ : ជ្រុងខាងកើតប្រវែង ១៥,៧០ម ជ្រុងខាងលិចប្រវែង ១៣,៨០ម ជ្រុងខាងជើងប្រវែង ៦៦,៥០ម ជ្រុងខាងត្បូងប្រវែង ៦៦,៣០ម ។ គិតពីថ្ងៃដែលសាលក្រមនេះ

ចូលជាស្ថាពរ ។

៣- រីបអូសប្រាក់ប្រដាប់ក្ដីដែលដើមចោទបង់រួចហើយគឺ : ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ រង្វាន់ប្រគល់ដីកាកោះ ចំនួន ២.០០០៛ ចំណាយស៊ើបសួរចំនួន ៣.០០០៛ សរុប ៧.០០០៛ ។

កាលបើប្ដឹងឧទ្ធរណ៍អោយដើមចោទឈ្មោះ ស៊ុន ហ៊ាង បង់ពន្ធសមាមាត្រចំនួន២០០០០៛ ប្រាក់នេះកាត់ ៨០ភាគរយ ដាក់ចូលថវិការដ្ឋ សល់២០ភាគរយដាក់ចូលហិបប្រាក់ក្រឡាបញ្ជី ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមស្មារតីអនុក្រឹត្យលេខ ២៥អ.ន.ក្រ ចុះថ្ងៃទី ២២.៤.៨៩ តាមមាត្រា ៣, ១៩, ៦១, ៦២, ៦៤, ៦៥, ៦៦, ៦៨ និង ៧១ នៃច្បាប់ភូមិបាលដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ ១០០ក្រ ចុះថ្ងៃទី ១៣.១០.១៩៩២ និងតាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដីដែលប្រកាស អោយប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨.០២.១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋ កម្ពុជា ។

៣- សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខគូក្ដី ។

បើកផ្លូវឧទ្ធរណ៍កំណត់រយៈពេលពីរខែ គិតពីថ្ងៃដែលប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៦៤ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៥ របស់អ្នកស្រី- ស៊ុន ហ៊ាង ត្រង់ចំណុចទី២ និងទី ៣ នៃសាលក្រមរបស់តុលាការខេត្តបាត់ដំបង ។

បានឃើញសាលដីកាលេខ ៥៣៦ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៩៩៨ របស់សាលា- ឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ១៤.៧.៩៥ របស់ឈ្មោះ ស៊ុន ហ៊ាង ទុកជាត្រឹម- ត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៤៨ ចុះថ្ងៃទី ១៤.៧.៩៥ របស់តុលាការ ខេត្តបាត់ដំបងទុកជាបានការដដែល ។

៣- កាត់បកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្ដឹង បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិប- ប្រាក់ចំនួន ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង លើអាជ្ញា ធរតុលាការចំនួន ៥.០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ កំបាំងមុខដើមបណ្ដឹងឧទ្ធរណ៍ ចំពោះមុខចុងបណ្ដឹងឧទ្ធរណ៍ ។ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៣៣៨ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ១៩៩៨ របស់អ្នកស្រី- ស៊ុន ហ៊ាង ប្ដឹងមិនសុខចិត្តនឹងសេចក្ដីសំរេចនៃសាលដីកាលេខ ៥៣៦ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩៨៨ របស់ឈ្មោះ ស៊ិន ហ៊ាង ។

បានឃើញសារណាតបចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨៩របស់ឈ្មោះទី ឈាន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ-៥៣៦ ចុះថ្ងៃទី ១៧.៨.៨៨របស់សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ស៊ិន ហ៊ាង ជាដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ ដែលបានឆ្លើយនៅពេលសវនាការថា : សាលាឧទ្ធរណ៍កាត់ក្តីអយុត្តិធម៌ពេលខ្លួនមកមិនកាត់ ។ ពីដំបូងប្រធានភូមិបានខ្ចីខ្លួនយកមកធ្វើសាលារៀនបណ្តោះអាសន្ន ។ ក្រោយមកខ្លួនដាំពោត សណ្តែក នៅទីនោះដល់មកឆ្នាំម្នាក់ការកូនខ្លួនមកប្រាប់ប្រធានភូមិថាអញសុំផ្ទះវិញហើយ ពេលនោះប្រធានភូមិថាឃាយឯងមកផ្តិតមេដៃអោយខ្លួនមកខ្លួនអោយឯតម្លឹង ។ ទី ឈាន ចង់លក់ទាំងដី ទាំងផ្ទះ ខ្លួននៅរ៉ូវតាតាំង ខេត្តបាត់ដំបង ។

បានស្តាប់ចម្លើយរបស់លោក ទី ឈាន ជាចុងចម្លើយ និង ជាចុងបណ្តឹងសាទុក្ខ ដែលបានឆ្លើយនៅពេលសវនាការថា : បញ្ហាថាខ្លួនយកផ្ទះនោះទៅធ្វើទ្រព្យសម្បត្តិឯកជនពុំអាចយកបានទេ ។ ដូចជាការលើកឡើងថាមេភូមិទៅខ្ចីគាត់គឺជាការពុំត្រឹមត្រូវទេដោយផ្ទះនេះរដ្ឋអំណាចយកធ្វើជាសាលារៀន មន្ទីរពាណិជ្ជកម្ម សាលាឃុំជាដើម ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ៣៣៤ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៨៨ របស់អ្នកស្រី ស៊ិន ហ៊ាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលអ្នកស្រី ស៊ិន ហ៊ាង បានចេញពីដី និង ផ្ទះនេះតាំងពីឆ្នាំ ១៩៧៥ ឬ ១៩៨០ រហូតមក អ្នកស្រីរូបនេះធ្លោះសិទ្ធិជាម្ចាស់លើដី និង ផ្ទះនេះតាមមាត្រា ៧៦ នៃច្បាប់ភូមិបាលហើយ ក្នុងករណីដែលមានការខ្ចីប្រើប្រាស់ក៏ដោយក៏ការទើបតែប្តឹងទាមទារនាឆ្នាំ ១៩៨២ នេះ អ្នកស្រីធ្លោះសិទ្ធិក្នុងការប្តឹងទាមទារតាមមាត្រា២៥ នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យាហើយដែរ ។

- យល់ឃើញថា : តាមកំណត់ហេតុចុះថ្ងៃទី ៩.៧.៨៥ ស្តីពីការលើកទីស្នាក់ការឃុំ

ឃើញថាលទ្ធផលការដាក់ទៅភូមិឃុំដីរាំនោះ ពុំមានបញ្ជាក់ថាម្ចាស់ផ្ទះដើមគឺអ្នកស្រី-ស៊ុន ហ៊ាង បានទៅមើលថែទាំង ឬ បេះផលដំណាំអ្វីលើដីទំនាស់នេះទេ ។

- យល់ឃើញថា : សាលដីការដ្ឋបួរទេវាណីលេខ ៥៣៦ ចុះថ្ងៃទី ១៧.៨.៩៨ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី ចំពោះមុខគូក្ដី

១_ ទទួលបណ្ដឹងសាទុក្ខលេខ ៣៣៤ ចុះថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ១៩៩៨ របស់អ្នកស្រី-ស៊ុន ហ៊ាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលដីការដ្ឋបួរទេវាណីលេខ ៥៣៦ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_ រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ស៊ុន ហ៊ាង បានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ៥.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល

បង្គាប់អោយអ្នកស្រី ស៊ុន ហ៊ាង បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តបាត់ដំបង ។

៤_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែសីហា - ឆ្នាំ ១៩៩៩ ។